អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គនាយកដ្ឋានស្រាវជ្រាវ

នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

➢ ការនាំចេញកៅស៊ូរបស់ប្រទេសកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិមានតម្លៃជិត១០០លានដុល្លារ គិតត្រឹមរយៈពេលបួនខែដំបូងនៃឆ្នាំ២០២១
➢ រោងចក្រនៅប្រទេសមីយ៉ាន់ម៉ាកំពុងសម្រុកផ្លាស់ប្តូរទីតាំងដំណើរការអាជីវកម្មមកកម្ពុជា
➢ កម្ពុជាផ្អាកនាំចូលសាច់បង្កកពីប្រទេសឥណ្ឌា
➢ ពាណិជ្ជកម្មរវាងកម្ពុជាជាមួយសហរដ្ឋអាមេរិកលើមុខទំនិញ នៅក្នុងខែកុម្ភៈ ឆ្នាំ២០២១
➢ កំណើនមិនស្របគ្នានៃសេដ្ឋកិច្ចអាស៊ីអាចបន្សល់ទុកបញ្ហាមួយចំនួនទៅថ្ងៃអនាគត
➢ សង្វាក់នៃការផ្គត់ផ្គង់របស់ពិភពលោកបន្តរើទីតាំងចេញពីប្រទេសចិន ប៉ុន្តែចិននៅតែជាប្រភពផ្គត់ផ្គង់សំខាន់
➢ សន្និសីទបារាំង នាថ្ងៃទី១៨ ខែឧសភា នឹងពិភាក្សាដោះស្រាយលើការជំរុញការងើបឡើងវិញនៃសេដ្ឋកិច្ចអាហ្វ្រិក
➢ ផែនការចំណាយលើកម្មវិធីសង្គម និងហេដ្ឋារចនាសម្ព័ន្ធរបស់លោក Biden ដែលមានតម្លៃសរុប ៤,៥ទ្រីលានដុល្លារ នឹងមិនដាក់បន្ទុកលើឱនភាពថវិកាសហព័ន្ធនោះឡើយ


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី	អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា	អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី	ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវរៈ	អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

ចងក្រង និងបូកសរុបដោយ

- ជីម ប៊ុនធឿន	ប្រធានការិយាល័យវិភាគចំណូល-ចំណាយ

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការនាំចេញកៅស៊ូរបស់ប្រទេសកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ មានតម្លៃជិត ១០០លានដុល្លារ គិតត្រឹមរយៈពេលបួនខែដំបូង នៃឆ្នាំ២០២១



*ប្រភព៖ postkhmer, 2021 រូបភាព៖ ហុង មិនា*

តាមទិន្នន័យដែលទទួលបានពីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានបង្ហាញថា នៅក្នុងរយៈពេលបួនខែដំបូង (មករា - មេសា) ឆ្នាំ២០២១ ការនាំចេញកៅស៊ូពីប្រទេសកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ មានតម្លៃ ៩៩,៨៧លានដុល្លារ ដែលមានការកើនឡើង២,៥% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ប៉ុន្តែបរិមាណកៅស៊ូដែលកម្ពុជាបានធ្វើការនាំចេញ គឺមិនបានកើនឡើងទេ ដោយមានចំនួនត្រឹម ៦១ ០៥៦តោន ពោលគឺធ្លាក់ចុះ១៥%។

លោក ម៉ែន សុភក្តិ ប្រធានក្រុមហ៊ុនដាំដុះ និងនាំចេញកៅស៊ូបានបញ្ជាក់ថា កំណើនតម្រូវការកៅស៊ូនៅក្នុងប្រទេសចិន ដែលជាទីផ្សារធំជាងគេលើពិភពលោក បានធ្វើឱ្យតម្លៃកៅស៊ូនៅកម្ពុជាកើនឡើងចាប់តាំងពីដើមឆ្នាំ២០២១មក ដែលតម្លៃកៅស៊ូ (ដឹកទៅដល់កំពង់ផែប្រទេសវៀតណាម) បានឡើងរហូតដល់ ១ ៨០០ដុល្លារក្នុង១តោន ធៀបនឹងឆ្នាំ២០២០ ដែលមានតម្លៃត្រឹម ១ ៤០០ដុល្លារក្នុង១តោន។

យោងតាមទិន្នន័យរបស់អគ្គនាយកដ្ឋានកៅស៊ូកម្ពុជា បានបង្ហាញថា បច្ចុប្បន្នកម្ពុជាមានផ្ទៃដីដាំដំណាំកៅស៊ូចំនួន ៤០៤ ១៥៩ហិកតា ក្នុងនោះផ្ទៃដីដែលអាចចៀរជ័របានមានចំនួន ២៩២ ៤៩៧ហិកតា ស្មើនឹង ៧២% និងផ្ទៃដីថែទាំមានចំនួន ១១១ ៦៦៣ហិកតា ស្មើនឹង២៨%។

ក្នុងឆ្នាំ២០២០ កម្ពុជាបាននាំចេញកៅស៊ូជាង ៣៥ម៉ឺនតោន ស្មើនឹង ៤៨២លានដុល្លារ ទៅកាន់ទីផ្សារប្រទេសចិន វៀតណាម សិង្ហបុរី និងម៉ាឡេស៊ី៕

*ដោយ សេន ចន្ទូ*

*ប្រភព៖ postkhmer.com, ចេញផ្សាយថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០២១*

## រោងចក្រនៅប្រទេសមីយ៉ាន់ម៉ាកំពុងសម្រុកផ្លាស់ប្តូរទីតាំងដំណើរការអាជីវកម្មមកកម្ពុជា



*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ២០២១, រូបភាព៖ យូសុះ អាប់ឌុលហ៉ស់ហ៊ីម*

យោងតាម លោក វ៉ី សំណាង អភិបាលខេត្តកំពង់ស្ពឺ បានបញ្ជាក់ថា ក្រុមវិនិយោគមកពីទីក្រុងហុងកុងបានជួបពិភាក្សាការងារជាមួយលោកកាលពីអំឡុងបុណ្យចូលឆ្នាំខ្មែរ ដើម្បីស្វែងរកទីតាំងប្រមាណជា ២០កន្លែងសម្រាប់ជួល ឬកន្លែងសមស្របណាមួយដើម្បីសាងសង់រោងចក្រដេរសម្លៀកបំពាក់ កាបូប និងស្បែកជើង ដែលអាចចាប់ដំណើរការអាជីវកម្មបានឆាប់។ ក្រុមវិនិយោគិនទាំងនោះ មានផែនការក្នុងការផ្ទេររោងចក្ររបស់ខ្លួនដែលកំពុងដំណើរការនៅប្រទេសមីយ៉ាន់ម៉ា មកកម្ពុជាដោយជ្រើសយកខេត្តកំពង់ស្ពឺ គឺជាជំរើសទី១។

លោកបានបន្ថែមថា ទោះក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ខេត្តកំពង់ស្ពឺនៅតែទទួលបានការមកបណ្តាក់ទុនជាបន្តបន្ទាប់ ដោយសារតែខេត្តមានស្ថេរភាពនយោបាយសុខសុវត្ថិភាពល្អ សម្បូរកម្លាំងពលកម្មជំនាញ មានទីតាំងភូមិសាស្ត្រអំណោយផល(នៅចន្លោះភ្នំពេញ និងកំពង់ផែទឹកជ្រៅ )និងមានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនល្អ។

បច្ចុប្បន្ន ខេត្តកំពង់ស្ពឺ មានរោងចក្រសហគ្រាសសរុបជាង៧ ៥០០ កំពុងប្រតិបត្តិការ ក្នុងនោះមានរោងចក្រសហគ្រាសធំៗចំនួន ៣៣៥ រោងចក្រ។ រោងចក្រសម្លៀកបំពាក់មានចំនួន ១៥៣ ដែលក្នុងនោះ រោងចក្រចំនួន ៤៣ ធ្វើការផលិតសម្រាប់នាំចេញទៅកាន់ទីផ្សារអាមេរិក និងក្រៅពីនោះ ផលិតសម្រាប់ការនាំចេញទៅទីផ្សារផ្សេងទៀត។

ទិន្នន័យពីក្រសួងពាណិជ្ជកម្មបានបង្ហាញថា ការនាំចេញផលិតផលសម្លៀកបំពាក់ ស្បែកជើង និងសម្ភារធ្វើដំណើរពីកម្ពុជាទៅទីផ្សារអន្តរជាតិក្នុងឆ្នាំ២០២០ ធ្លាក់ចុះ ១០,២៤% ១១,៦៩% និង ១០,៥៨ %រៀងគ្នា ធៀបនឹងឆ្នាំ២០១៩។ *ដោយ មុំ ចិន្តា*

*ប្រភព៖ ភ្នំពេញប៉ុស្តិ៍, ចេញផ្សាយថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០២១*

## កម្ពុជាផ្អាកនាំចូលសាច់បង្កកពីប្រទេសឥណ្ឌា



*ប្រភព៖ Khmer Times, 2021*

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់លោក គុណ ញឹម អគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា កាលពីថ្ងៃសៅរ៍ បានបញ្ជាក់ថា ប្រទេសកម្ពុជាបានប្រកាសដាក់បំរាមលើការនាំចូលសាច់បង្កក និងផលិតផលសាច់ពីប្រទេសឥណ្ឌាដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ នៅទូទាំងប្រទេស។

សេចក្តីសម្រេចខាងលើនេះត្រូវបានធ្វើឡើងបន្ទាប់ពីទិន្នន័យរបស់ក្រសួងសុខាភិបាលបានបង្ហាញថា នៅក្នុងប្រទេសឥណ្ឌាមានការកើនឡើងយ៉ាងខ្លាំងនូវករណីជំងឺកូវីដ-១៩ ដែលមានការឆ្លងថ្មីរហូតដល់ ៣៩២ ៤៨៨នាក់ និងការស្លាប់ចំនួន ៣ ៦៨៩នាក់ ក្នុងរយៈពេលត្រឹម ២៤ម៉ោង។

ការសម្រេចខាងលើនេះ ក៏បានធ្វើឡើងបន្ទាប់ពីកិច្ចប្រជុំ BSM តាមប្រព័ន្ធអនឡាញរវាង លោកស្រី Devyani Uttam Khobragade ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌាប្រចាំកម្ពុជា ជាមួយក្រុមហ៊ុនចំនួន ៦១ មកពីភាគីនៃប្រទេសទាំងពីរ ដោយមានការសម្របសម្រួលពីសភាពាណិជ្ជកម្មកម្ពុជា និងអាជ្ញាធរអភិវឌ្ឍន៍ការនាំចេញផលិតផលកសិកម្ម និងកែច្នៃ(APEDA) ។

នៅក្នុងកិច្ចប្រជុំនេះ លោក Madhaiyaan Angamuthu ប្រធាន APEDA បានបញ្ជាក់ថា យោងតាមគោលនយោបាយនាំចេញនិងនាំចូលរបស់រដ្ឋាភិបាលឥណ្ឌាបច្ចុប្បន្ន ការនាំចេញសាច់នីមួយៗត្រូវឆ្លងកាត់ការធ្វើតេស្តវិភាគមីក្រូជីវសាស្ត្រ (microbiologic) និងការធ្វើតេស្តផ្សេងទៀត។ ក្រៅពីនេះ សម្រាប់ការនាំចេញសាច់ទាំងអស់ត្រូវបានគ្រប់គ្រងផ្នែកគុណភាព អនាម័យ និងសុវត្ថិភាពចំណីអាហារ ព្រមទាំងមានការត្រួតពិនិត្យពីភ្នាក់ងាររដ្ឋាភិបាល និងបសុពេទ្យយ៉ាងច្បាស់លាស់។

ក្នុងរយៈពេលពីរខែដំបូងក្នុងឆ្នាំ២០២១នេះ ការនាំចេញសាច់ក្របីពីប្រទេសឥណ្ឌា មកប្រទេសកម្ពុជា បានកើនឡើងដល់ទំហំទឹកប្រាក់ចំនួន ៩,៣២លានដុល្លារ ហើយរំពឹងថា នឹងមានការកើនឡើងជាលំដាប់នៅប៉ុន្មានឆ្នាំខាងមុខនេះ។

ជាមួយគ្នានេះដែរ លោកស្រី Devyani Uttam Khobragade បានលើកឡើងថា ក្រុមហ៊ុនឥណ្ឌា នឹងអាចផ្គត់ផ្គង់ផលិតផលសាច់ និងសាច់ដែលមានគុណភាពល្អមកកម្ពុជាក្នុងតម្លៃថោកជាងមុន និងបង្កើនចំណែកទីផ្សារដែលកំពុងរីកចម្រើនរួចទៅហើយ។ ការធ្វើដូច្នេះបានចូលរួមចំណែកបន្ថែមទៀតក្នុងការពង្រឹងទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ។

លោកស្រីបានបន្ថែមទៀតថា កិច្ចសហប្រតិបត្តិការដែលបានពង្រឹងនៅក្នុងវិស័យកសិ-កែច្នៃនេះ មិនត្រឹមតែជាស្ថានភាពឈ្នះ-ឈ្នះសម្រាប់ប្រទេសទាំងពីរប៉ុណ្ណោះទេ គឺបានផ្តល់ឱកាសដល់ប្រទេសកម្ពុជាក្នុងការធ្វើពិពិធកម្មផលិតផលកសិកម្មបន្ថែមទៀតនៅក្នុងរយៈពេលមធ្យម និងវែង។

ស្របពេលជាមួយគ្នានោះដែរ លោក ម៉េង និមល ដែលជាអគ្គនាយករងសភាពាណិជ្ជកម្មកម្ពុជា បានលើកទឹកចិត្តក្រុមហ៊ុននៃភាគីទាំងពីរឱ្យធ្វើអន្តរកម្មជាមួយគ្នា

ដើម្បីស្វែងរកឱកាសធុរកិច្ចសម្រាប់ពង្រីកទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរបន្ថែមទៀត៕

*ដោយ មុំ ចិន្តា*

*ប្រភព៖ ខ្មែរថាមស៍, ចេញផ្សាយថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១*

## តារាងប្រចាំសប្តាហ៍៖ ពាណិជ្ជកម្មរវាងកម្ពុជាជាមួយសហរដ្ឋអាមេរិកលើមុខទំនិញ នៅក្នុងខែកុម្ភៈ ឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់ការិយាល័យជំរឿនសហរដ្ឋអាមេរិកបង្ហាញថា នៅក្នុងខែកុម្ភៈ ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជាជាមួយសហរដ្ឋអាមេរិកមានទំហំទឹកប្រាក់ប្រមាណជា ៥៧២,៧លានដុល្លារ ដែលមានការធ្លាក់ចុះប្រមាណជា ៦,៨% បើធៀបនឹងខែមករា។

ជាក់ស្តែង នៅក្នុងខែកុម្ភៈ ឆ្នាំ២០២១ ការនាំចេញទំនិញរបស់ប្រទេសកម្ពុជាទៅសហរដ្ឋអាមេរិកមានទំហំទឹកប្រាក់ប្រមាណជា ៥៣៩,៤លានដុល្លារ ដែលមានការធ្លាក់ចុះប្រហែល ៧,១% បើធៀបនឹងខែមករា។ ការនាំចេញនេះភាគច្រើនជាប្រភេទទំនិញសម្រាប់ធ្វើដំណើរ (កាបូបយួរ កាបូបលុយ និងគ្រឿងអលង្ការ) ខោអាវ ស្បែកជើង និងផលិតផលផ្សេងៗទៀត។

ស្របពេលនោះដែរ ការនាំចូលទំនិញរបស់សហរដ្ឋអាមេរិកមកកម្ពុជាមានទំហំទឹកប្រាក់ ៣៣,៣លានដុល្លារ ដែលមានការធ្លាក់ចុះបន្តិចប្រមាណជា ១,៨% បើធៀបនឹងខែមករា។ ការនាំចូលទំនិញសំខាន់ៗ រួមមាន៖ រថយន្តធ្វើដំណើរ គ្រឿងបន្លាស់យានយន្ត ទឹកដោះគោ និងផលិតផលផ្សេងៗទៀត៕ *ដោយ មិត្ត ចន្ទី*

| **បរិយាយ** | មករា | កុម្ភៈ | កំណើន/ថយ |
|---|---|---|---|
| ទំហំពាណិជ្ជកម្ម | 614.5 | 572.7 | -6.8% |
| នាំចូល | 33.9 | 33.3 | -1.8% |
| នាំចេញ | 580.6 | 539.4 | -7.1% |

*ប្រភព៖ ការិយាល័យជំរឿនសហរដ្ឋអាមេរិក និងទិន្នន័យណិជ្ជកម្មសហរដ្ឋអាមេរិក (គិតជាលានដុល្លារ)*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### កំណើនមិនស្របគ្នានៃសេដ្ឋកិច្ចអាស៊ីអាចបន្សល់ទុកបញ្ហាមួយចំនួនទៅថ្ងៃអនាគត




*ការនាំចេញផលិតផលរបស់ប្រទេសកូរ៉េនៅក្នុងត្រីមាសទី១ កើនឡើងខ្ពស់ជាងត្រីមាសទី៤ ឆ្នាំ២០១៩ ចំនួន ៤,៤%។ រូបថតដោយ៖ YONHAP/SHUTTERSTOCK*

កាលពីសប្តាហ៍កន្លងទៅ កំណើនសេដ្ឋកិច្ចរបស់ប្រទេសកូរ៉េខាងត្បូង និងកោះតៃវ៉ាន់មានលក្ខណៈល្អប្រសើរជាងការរំពឹងទុក។ សេដ្ឋកិច្ចនៃប្រទេសទាំងពីរនៅក្នុងពេលនេះមានស្ថានភាពប្រហាក់ប្រហែលគ្នា។ ការនាំចេញនៅតែបន្តមានកំណើនខ្ពស់ ខណៈដែលតម្រូវការ

ក្នុងស្រុកមិនមានការកើនឡើង។ បើនិន្នាការនេះនៅតែបន្ត នោះសេដ្ឋកិច្ចនៃប្រទេសទាំងពីរនឹងប្រឈមនឹងបញ្ហា។ បើធៀបទៅនឹងស្ថានភាពមុនពេលរងគ្រោះដោយសារវិបត្តិជំងឺកូវីដ-១៩ ការនាំចេញទំនិញរបស់ប្រទេសកូរ៉េខាងត្បូងនៅក្នុងត្រីមាសទី១ ឆ្នាំ២០២១ កើនឡើងខ្ពស់ជាងត្រីមាសទី៤ នៃឆ្នាំ២០១៩ ចំនួន ៤,៤% ប៉ុន្តែ ការចំណាយរបស់អ្នកប្រើប្រាស់នៅក្នុងវិស័យឯកជនមានកម្រិតធ្លាក់ចុះ ៥,៥% ធៀបនឹងរយៈពេលដូចគ្នានោះ។ ស្រដៀងគ្នានេះដែរ ការនាំចេញគ្រឿងអេឡិចត្រូនិចប្រចាំឆ្នាំរបស់កោះតៃវ៉ាន់ មានការកើនឡើង ២៨,៤%។ កំណើននៃការនាំចេញសរុបបានចូលរួមចំណែកដល់កំណើន ផ.ស.ស. ដល់ទៅ ៨,២% ច្រើនជាងការចំណាយលើការប្រើប្រាស់។

ប៉ុន្តែសម្រាប់ប្រទេសមួយចំនួនដូចជាសហរដ្ឋអាមេរិក និងអង់គ្លេស ដែលឱនភាពពាណិជ្ជកម្មជាធម្មតាមានទំហំធំ អាចប្រហែលជារឿងល្អវិញទេ នៅពេលកើតមានករណីដូចក្នុងប្រទេសកូរ៉េ និងកោះតៃវ៉ាន់។ ប៉ុន្តែទោះយ៉ាងណា អតុល្យភាពនេះក្នុងទិសដៅណាមួយនឹងបង្កឱ្យមានបញ្ហាមួយចំនួន។

បញ្ហាទាំងនេះកើតឡើងដោយសារតែការធ្លាក់ចុះនៃទីផ្សាររូបិយប័ណ្ណបរទេស។ ឧទាហរណ៍៖ ទីក្រុងសេអ៊ូល និងតៃប៉ិ តែងតែព្យាយាមទប់មិនឱ្យរូបិយវត្ថុរបស់ខ្លួនហក់ឡើងខ្ពស់ពេក ដែលនាំឱ្យមានសំពាធ ឬគាបសង្កត់ដល់ការប្រកួតប្រជែងចំពោះការនាំចេញ។ បញ្ហាទីមួយ គឺទុនបម្រុងរូបិយប័ណ្ណបរទេសបន្តកើនឡើងខ្លាំង ដែលជាហេតុនាំឱ្យប្រទេសនាំចេញទាំងពីរអាចនឹងមានការប៉ះទង្គិចគ្នាជាមួយសហរដ្ឋអាមេរិកទាក់ទងទៅនឹងការគ្រប់គ្រងតម្លៃរូបិយប័ណ្ណ។ ថ្វីត្បិតតែ បញ្ហានេះអាចមិនកើតឡើងភ្លាមៗ ប៉ុន្តែធនាគារជាតិរបស់សហរដ្ឋអាមេរិកប្រហែលជានឹងមិននៅស្ងៀមអោបដៃចាំមើលឡើយ។

ដោយឡែក បញ្ហាទីពីរមានភាពស្មុគស្មាញជាងបញ្ហាទីមួយ និងជាក្តីបារម្ភសម្រាប់រយៈពេលវែង។ ធនាគារកណ្តាលរបស់កូរ៉េខាងត្បូង និងតៃវ៉ាន់ តែងតែមានគោលបំណងចង់ដំឡើងអត្រាការប្រាក់។ ប៉ុន្តែធនាគារកណ្តាលទាំងពីរនេះបែរជានៅតែរក្សាអត្រាការប្រាក់ទាបបំផុត និងពឹងផ្អែកលើការអនុវត្តគោលនយោបាយរូបិយវត្ថុ ជាជាងការអនុវត្តគោលនយោបាយសារពើពន្ធដើម្បីគាំទ្រតម្រូវការក្នុងស្រុក ដែលជាលទ្ធផល ឥរិយាបថនេះទំនងជាអាចនឹងធ្វើឱ្យភាពងាយរងគ្រោះរបស់វិស័យហិរញ្ញវត្ថុកាន់តែមានស្ថានភាពអាក្រក់ទៅ ដោយជាប់ពាក់ព័ន្ធទៅនឹងទីផ្សារលំនៅឋាន។ ជាក់ស្តែងបំណុលទិញផ្ទះរបស់ប្រជាពលរដ្ឋនៅតៃវ៉ាន់កាលពីឆ្នាំ២០១៩ មានទំហំស្មើនឹង ៨៦,៧% នៃ ផ.ស.ស. ប៉ុន្តែ បំណុលដែលមិនទាន់សងសរុបមានកំណើន ១០% គិតចាប់តាំងពីចាប់ផ្តើមមានវិបត្តិជំងឺកូវីដ-១៩ រហូតមកដល់ពេលនេះ នឹងអាចបន្តកើនឡើង។ ខណៈដែលបំណុលទិញផ្ទះនៅកូរ៉េខាងត្បូងនៅចុងឆ្នាំ២០២០ មានទំហំដល់ទៅ១០២,៨% នៃផ.ស.ស.។ សរុបមក តួលេខនេះមានកម្រិតខ្ពស់ បើធៀបទៅនឹងស្តង់ដារនៅតាមបណ្តាប្រទេស ដែលមានសេដ្ឋកិច្ចជឿនលឿន។

ជារួម រដ្ឋាភិបាលរបស់កូរ៉េខាងត្បូង និងតៃវ៉ាន់ បានព្យាយាមរក្សាស្ថិរភាពទីផ្សារលំនៅដ្ឋានម្តងហើយម្តងទៀត ដោយមើលឃើញថា អស្ថិរភាពទីផ្សារលំនៅដ្ឋានអាចបង្កផលប៉ះពាល់ដ៏ធំ។ ប៉ុន្តែនៅពេលដែលរដ្ឋាភិបាលដាក់ចេញនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចជាច្រើនលើសលុប ដើម្បីជៀសវៀងបំណុលសាធារណៈ និងផ្តោតអាទិភាពខ្លាំងពេកលើកំណើននៃការនាំចេញ ភាពងាយរងគ្រោះកាន់តែកើនឡើង ដោយមិនអាចជៀសផុត។ *ដោយ វង្ស ច័ន្ទរស្មីដារា*

*ប្រភព៖ គេហទំព័រ The Wall Street Journal, ចេញផ្សាយថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០២១*

## សង្វាក់នៃការផ្គត់ផ្គង់របស់ពិភពលោកបន្តរើទីតាំងចេញពីប្រទេសចិន ប៉ុន្តែចិននៅតែជាប្រភពនៃការផ្គត់ផ្គង់លំដាប់កំពូល



*កម្មករកម្មការិនីនៅប្រទេសវៀតណាមកំពុងត្រួតពិនិត្យគុណភាពទូរស័ព្ទឆ្លាតវៃ។ ប្រទេសវៀតណាមត្រូវបានគេប្រសិទ្ធិនាមថា ជាប្រភពទីផ្សារទីបីរបស់ពិភពលោក នេះបើយោងតាមការឆ្លើយសំណួររបស់ប្រជាពលរដ្ឋចំនួនមួយភាគបួននៅក្នុងការស្ទង់មតិមួយរបស់ពិភពលោក។ រូបថតដោយ៖ Bloomberg*

បើទោះបីជាសេដ្ឋកិច្ចរបស់ចិនបានស្ទុះងើបឡើងវិញក្នុងល្បឿនមួយយ៉ាងលឿនបន្ទាប់ពីរងគ្រោះដោយសារវិបត្តិជំងឺកូវីដ-១៩ និងមានសញ្ញាណល្អប្រសើរជាងបណ្តាប្រទេសនៅលោកខាងលិចក្តី ក៏និន្នាការនៃការធ្វើពិពិធកម្មរយៈពេលវែង លើសង្វាក់នៃការផ្គត់ផ្គង់របស់ពិភពលោកនៅតែបន្តចាកចេញពីប្រទេសចិន ដែលជាមហាអំណាចសេដ្ឋកិច្ចលំដាប់ទី២ នេះបើយោងតាមការស្ទង់មតិរបស់ Qima កាលពីខែមីនាកន្លងទៅ ដែលបានធ្វើឡើងជាង ៧០០ក្រុមហ៊ុន នៅលើពិភពលោក។

នៅក្នុងឆ្នាំ២០១៩ ក្រុមហ៊ុននៅសហរដ្ឋអាមេរិកចំនួន ៩៦% និងក្រុមហ៊ុនដែលមានទីតាំងនៅតំបន់អឺរ៉ុប ១០០% បានចាត់ថ្នាក់ចិនជាប្រទេសមួយនៅក្នុងចំណោមប្រទេសទាំងបីលំដាប់កំពូល ដែលជាប្រភពនៃការផ្គត់ផ្គង់។ ប៉ុន្តែភាគរយនេះបានធ្លាក់ចុះមកនៅត្រឹមតែ ៧៧% និង៨០% នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១ នេះបើយោងតាមការស្ទង់មតិរបស់ Qima។ មូលហេតុបណ្តាលមកពីភាពរង្គោះរង្គើនៅក្នុងសង្គ្រាមពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិក និងការធ្លាក់ចុះប្រជាប្រិយភាពនៃទីផ្សាររបស់ចិនសម្រាប់ពួកលោកខាងលិច នៅដើមឆ្នាំ២០២០ ដែលបណ្តាលមកពីការរងគ្រោះដោយសារការបិទខ្ទប់ ព្រោះតែវិបត្តិជំងឺកូវីដ-១៩។

ប៉ុន្តែបើទោះបីជាក្រុមហ៊ុននៅសហរដ្ឋអាមេរិក និងអឺរ៉ុប កាត់បន្ថយការពឹងផ្អែកលើទីផ្សាររបស់ចិនក្តី ក៏ចិននៅតែជាប្រភពនៃការផ្គត់ផ្គង់ដែលជាប់ចំណាត់ថ្នាក់កំពូលដដែល។ ចំពោះក្រុមហ៊ុនដែលមិនស្ថិតនៅក្នុងប្រទេសចិន ដែលបានចូលរួមក្នុងការស្ទង់មតិបានបង្ហាញថា

ជាង ៨៥% នៅតែចាត់ទុកចិនជាប្រទេសមួយក្នុងចំណោមប្រទេសកំពូលបីនៃប្រភពនៃការផ្គត់ផ្គង់ដល់ពួកគេ ជាពិសេសចំពោះផលិតផលក្មេងលេង គ្រឿងអេឡិចត្រូនិក និងផលិតផលបញ្ចុះតម្លៃ។ មូលហេតុដែលនាំឱ្យចិននៅតែមានប្រជាប្រិយភាព និងនៅតែអាចឈរឈ្មោះជាប្រភពនៃការផ្គត់ផ្គង់ ទីមួយ៖ គឺដោយសារសេដ្ឋកិច្ចចិនឆ្លើយតបបានត្រឹមត្រូវ និងឆាប់ងើបឡើងវិញពីវិបត្តិជំងឺកូវីដ-១៩។ ទីពីរ៖ ដោយសារក្រុមហ៊ុនមួយចំនួនបាន សហការជាមួយចិនយូរមកហើយ ទីបី៖ កំណត់ត្រាល្អនៃគុណភាពផលិតផលរបស់ចិនធៀបទៅនឹងប្រទេសក្នុងតំបន់ និងទី៤៖ វឌ្ឍនភាពរបស់ចិនចំពោះការគោរពក្រមសីលធម៌នៅក្នុងការរកស៊ីមានភាពចាស់ទុំជាងប្រទេសផ្សេងទៀតនៅក្នុងតំបន់ដែលជាប្រភពនៃការផ្គត់ផ្គង់។

ទោះជាយ៉ាងណា គេសង្កេតឃើញថា ក្រៅពីចិន មានប្រទេសវៀតណាមមួយទៀត ដែលជាជម្រើសប្រភពនៃទីផ្សារការផ្គត់ផ្គង់នៅក្នុងតំបន់។ គួរបញ្ជាក់ថា វៀតណាមរក្សាបានប្រជាប្រិយភាពរបស់ខ្លួនក្នុងអំលុងឆ្នាំ២០២០រហូតដល់ដើមឆ្នាំ២០២១ និងត្រូវបានគេប្រសិទ្ធិនាមថាជាប្រទេសមួយនៅក្នុងចំណោមប្រទេសទាំងបី ដែលជាប្រភពនៃការផ្គត់ផ្គង់ធំជាងគេ។ គួររំលឹកថា តាំងពីមុនពេលមានសង្គ្រាមពាណិជ្ជកម្មរវាងចិន និងសហរដ្ឋអាមេរិក ក្រុមហ៊ុនចិនមួយចំនួន ជាពិសេស ប្រភេទឧស្សាហកម្មកាត់ដេរ និងវាយនភ័ណ្ឌ បានប្តូរទីតាំងផលិតរបស់ខ្លួនមកកាន់បណ្តាប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ ដូចជា វៀតណាមជាដើម។ មិនត្រឹមតែប៉ុណ្ណោះ រោងចក្រសហគ្រាសជាច្រើនប្រភេទផ្សេងទៀត បានផ្លាស់ប្តូរទីតាំងផលិតរបស់ខ្លួនទៅប្រទេសវៀតណាម ចាប់តាំងពីពិភពលោកកើតមានសង្គ្រាមពាណិជ្ជកម្មមកម្លេះ។ ខណៈដែលឥណ្ឌា ដែលជាប្រភពឧស្សាហកម្មវាយនភ័ណ្ឌ និងត្រូវបានគេស្គាល់ថា ជាប្រទេសដែគូឈានមុខគេនៅក្នុងការផលិតផលិតផលប្រភេទស្បែកជើង គ្រឿងអលង្ការ វ៉ែនតា និងសម្ភារច្នៃម៉ូដកំពុងតែរងការវាយប្រហារពីវីរុសកូវីដ-១៩យ៉ាងខ្លាំងក្លា។ គួរបញ្ជាក់ផងដែរថា វៀតណាម មានប្រជាប្រិយភាពយ៉ាងខ្លាំងចំពោះពាណិជ្ជកម្ម ដែលមានប្រភពមកពីសហរដ្ឋអាមេរិក ពីព្រោះ កន្លងមកចំនួនអាជីវកម្មដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិកដែលបានចាត់ទុកវៀតណាមជាប្រភពនៃការផ្គត់ផ្គង់ បានកើនឡើងស្ទើរតែទ្វេរដងនៅក្នុងអំលុងពេល៤ឆ្នាំចុងក្រោយ ពោលគឺកើនដល់៤៣% នៅដើម ឆ្នាំ២០២១នេះ។ ទន្ទឹមនឹងនេះ ២៥%នៃក្រុមហ៊ុនដែល មានមូលដ្ឋាននៅអឺរ៉ុបបានចាត់ទុកប្រទេសវៀតណាមជាប្រភពទីផ្សារផ្គត់ផ្គង់ ដែលឈរនៅក្នុងចំណោមប្រទេសខ្ពស់ជាងគេចំនួនបីនៅក្នុងត្រីមាសទី១ ទាបជាងឆ្នាំមុន ១៥ពិន្ទុភាគរយ ប៉ុន្តែខ្ពស់ជាងឆ្នាំ២០១៩ ដែលមានចំនួនត្រឹម ១១%។ នេះគឺដោយសារវៀតណាម និងសហភាពអឺរ៉ុបបានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាមួយគ្នាកាលពីថ្ងៃទី១ ខែសីហា។

សរុបមក នៅក្នុងចំណោមក្រុមហ៊ុន ដែលបានផ្លាស់ប្តូរអ្នកផ្គត់ផ្គង់ទៅកាន់ភូមិសាស្ត្រថ្មី ដើម្បីគេចពីការរំខានពីជំងឺកូវីដ-១៩ និងហានិភ័យផ្សេងៗ ស្ទើរតែមួយភាគបីបានចាត់ទុកវៀតណាមជាជម្រើសមួយនៅក្នុងចំណោម

ជម្រើសនៃទីផ្សារផ្គត់ផ្គង់ ដែលជាប់លំដាប់ថ្នាក់ខ្ពស់បំផុត ជាពិសេសក្រុមហ៊ុននៅសហរដ្ឋអាមេរិកមានចំនួនដល់ទៅជាង ៤០% នេះបើយោងតាមការស្ទង់មតិ។ និន្នាការនេះ ហាក់ដូចជានៅតែបន្តនៅក្នុងឆ្នាំ២០២១នេះ។ នៅក្នុងអំលុងពេល ១២ខែខាងមុខនេះ ក្រុមហ៊ុនចំនួន ៣៨% នៅសហរដ្ឋអាមេរិក និង២៨% នៅអឺរ៉ុបមានផែនការផ្លាស់ប្តូរការផលិតរបស់ពួកគេទៅកាន់ប្រទេសវៀតណាម ឬធ្វើការបញ្ជាទិញបន្ថែមពីអ្នកផ្គត់ផ្គង់ ដែលមានស្រាប់នៅប្រទេសវៀតណាមតែម្តង។ ទន្ទឹមនឹងនេះដែរ អាជីវកម្មផ្សេងៗទៀតមិនមានបំណងវិលត្រលប់ទៅកាន់ប្រទេសចិនវិញទេ។ នៅសហរដ្ឋអាមេរិកមានក្រុមហ៊ុនតែ ៦% និងនៅអឺរ៉ុប ១១% ប៉ុណ្ណោះ ដែលនិយាយថាបានបន្ថែមប្រភពនៃការផ្គត់ផ្គង់របស់ពួកគេពីចិននៅក្នុងឆ្នាំ២០២០។

ទោះជាយ៉ាងណា ផែនការ និងការអនុវត្តហាក់ដូចជាមានភាពមិនច្បាស់លាស់។ សរុបទៅនៅក្នុងឆ្នាំ២០២០ មានក្រុមហ៊ុន ៧៣% ដែលបានធ្វើការស្ទង់មតិតាមរយៈ Qima មានផែនការស្វែងរកប្រទេសថ្មី ដើម្បីធ្វើជាប្រភពនៃការផ្គត់ផ្គង់ ប៉ុន្តែមានតែ ៣៨% ប៉ុណ្ណោះ ដែលបានអនុវត្តផែនការនេះ។ ដោយឡែកចំពោះក្រុមហ៊ុននៅសហរដ្ឋអាមេរិកដល់ទៅ៨៣% បាន ប្រកាសធ្វើពិពិធកម្មភូមិសាស្ត្រនៅដើមឆ្នាំ២០២០ ប៉ុន្តែ មានតែ ៤៩% ប៉ុណ្ណោះដែលបានអនុវត្តផែនការនេះ៕

*ដោយ វង្ស ច័ន្ទរស្មីដារា*

*ប្រភព៖ គេហទំព័រ South China Morning Post, ចេញផ្សាយថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### សន្និសីទបារាំង នាថ្ងៃទី១៨ ខែឧសភា នឹងពិភាក្សាដោះស្រាយលើការជំរុញការងើបឡើងវិញនៃសេដ្ឋកិច្ចអាហ្វ្រិក



*ប្រភព៖ Reuters ២០២១, រូបភាព៖ Sarah Meyssonnier*

យោងតាមរដ្ឋមន្ត្រីសេដ្ឋកិច្ចបារាំង លោក Bruno Le Maire បានលើកឡើងកាលពីថ្ងៃទី៣០ ខែមេសា ថា សន្និសីទដែលនឹងរៀបចំឡើងនៅប្រទេសបារាំង នៅពាក់កណ្តាលខែឧសភា នឹងធ្វើការដោះស្រាយជួយដល់សេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស ប្រទេសនៅអាហ្វ្រិក កុំឱ្យធ្លាក់ចុះឆ្ងាយពីការងើបឡើងវិញនៃសេដ្ឋកិច្ចសកល។ បន្ថែមពីនេះ លោកបានបន្តថា សន្និសីទនេះ នឹងសម្លឹងមើលរកវិធីសាស្រ្ត ក្នុងការជួយគាំទ្រដល់ក្រុមហ៊ុនធុនតូច និងមធ្យម ដោយសារតែអាជីវកម្មទាំងនេះបានជួបប្រទះនឹងបញ្ហាលំបាក ក្នុងការទទួលបានហិរញ្ញប្បទាន ដែលបានរុញច្រានភាពមានការងារធ្វើធ្លាក់ចុះ ៨,៥% និងប្រទេសចំនួន ១៧ ក្នុងទ្វីបនេះបានស្ថិតក្នុង ឬស្ទើរតែធ្លាក់ទៅក្នុងវិបត្តិបំណុលដែលមិនអាចសងរួច (Debt Distress)។

ដោយឡែក មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) ក៏បានផ្តល់ជំនួយហិរញ្ញប្បទានផ្ទាល់ ដែលមានទឹកប្រាក់សរុប ២៣ប៊ីលានដុល្លារ ទៅដល់តំបន់អនុសាហារ៉ា អាហ្វ្រិក (sub-Saharan Africa) ដែលសេដ្ឋកិច្ចរួមរបស់តំបន់នេះ បានធ្លាក់ចុះ ១,៩% ក្នុងឆ្នាំ២០២០ ដែលជាការធ្លាក់ចុះអាក្រក់បំផុត នៅក្នុងកំណត់ត្រា៕

*ដោយ ជា សិរីរតន៍*

*ប្រភព៖ Reuters, ចេញផ្សាយថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២១*

## ផែនការចំណាយលើកម្មវិធីសង្គម និងហេដ្ឋារចនាសម្ព័ន្ធរបស់លោក Biden ដែលមានតម្លៃសរុប ៤,៥ទ្រីលានដុល្លារ នឹងមិនដាក់បន្ទុកលើឱនភាពថវិកាសហព័ន្ធនោះឡើយ



*ប្រភព៖ Wall Street Journal ២០២១, រូបភាព៖ Melina Mara*

ថ្មីៗនេះ ប្រធានាធិបតីអាមេរិក លោក Biden បានធ្វើការដាក់សំណើផែនការចំណាយលើកម្មវិធីសង្គម និងកម្មវិធីហេដ្ឋារចនាសម្ព័ន្ធ ដែលមានតម្លៃសរុប ៤,៥ទ្រីលានដុល្លារ បន្ទាប់ពីកញ្ចប់សង្គ្រោះសេដ្ឋកិច្ច ១,៩ទ្រីលានដុល្លារ ដែលត្រូវបានហិរញ្ញប្បទានទាំងស្រុងពីការខ្ចី។ ទន្ទឹមនេះដែរ ប្រធានាធិបតី Biden បានលើកឡើងថា ផែនការចំណាយនេះ នឹងមិនបង្កើនឱនភាពថវិកានោះឡើយ ដោយហិរញ្ញប្បទានលើផែនការចំណាយសម្រាប់កម្មវិធីទាំងពីរនេះ គាំទ្រដោយការបង្កើនពន្ធមួយចំនួនលើអ្នកមានទ្រព្យសម្បត្តិ និងសាជីវកម្ម។

ដោយឡែក បើយោងតាមការប៉ាន់ស្មានរបស់អ្នកវិភាគមកពីគណៈកម្មាធិការថវិកាសហព័ន្ធមានទំនួលខុសត្រូវ (Committe for a Responsible Federal Budget, CRFB) និងស្ថាប័នស្រាវជ្រាវម៉ាក្រូ Cornerstone បង្ហាញថា សំណើរផែនការចំណាយថ្មីនេះ នឹងអាចបង្កើនឱនភាពថវិកាសហព័ន្ធប្រហែលជា ១,៣ទ្រីលានដុល្លារ នៅក្នុងរយៈពេល១០ឆ្នាំខាងមុខ។ បន្ថែមពីនេះទៀត អ្នកវិភាគបានបន្តថា ឱនភាពនេះនឹងអាចត្រូវបានបំពេញនៅប៉ុន្មានឆ្នាំខាងមុខ តាមរយៈការធ្លាក់ចុះជាសន្សឹមៗនៃចំណាយ និងការបន្តកើនឡើងនៃចំណូលពន្ធ រីឯបំណុលសហព័ន្ធវិញ នឹងអាចចាប់ផ្តើមធ្លាក់ចុះ ធៀបនឹងផលិតផលក្នុងស្រុកសរុប (ផ.ស.ស.)។

យោងតាមលោក Marc Goldwein អនុប្រធានជាន់ខ្ពស់នៃ CRFB បានលើកឡើងថា ក្របខណ្ឌនៃសំណើផែនការចំណាយនេះ គឺផ្តោតលើការចំណាយមុន ការបង្កើតវិនិយោគក្នុងចំនួនច្រើន ជាមួយនឹងការរំពឹងថានឹងទទួលបានផលចំណេញសេដ្ឋកិច្ចនិរន្តន៍ និងកាត់បន្ថយបំណុលរយៈពេលវែង។ ប៉ុន្តែ លោកក៏បានបន្តថា វាគឺមានភាពប្រថុយប្រថាន និងគ្រោះថ្នាក់ណាស់ក្នុងការពឹងផ្អែកលើចំណូលអនាគតដែលមានរយៈពេលវែងជាង១០ឆ្នាំ។

ទន្ទឹមនេះដែរ គណបក្សសាធារណរដ្ឋ បានលើកឡើងថា ការកំហិតចំណាយ គឺមានភាពចាំបាច់ក្នុងការចូលរួមទប់ស្កាត់ការបន្តកើនឡើងនៃបំណុលសហព័ន្ធ និង បានព្រមានថា ការបង្កើនពន្ធ នឹងអាចកាត់បន្ថយការវិនិយោគឯកជន ដែលជាលទ្ធផល នឹងប៉ះពាល់ទៅលើសេដ្ឋកិច្ច៕ *ដោយ ជា សិរីតែន៍*

*ប្រភព៖ Wall Street Journal, ចេញផ្សាយថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ អត្រាគ្មានការងារធ្វើនៅប្រទេសទួរគី ការរំពឹងទុកអតិផរណាទំនិញប្រើប្រាស់ និងការបម្រែបម្រួលភាគហ៊ុនប្រេងឆៅ API របស់សហរដ្ឋអាមេរិក ការលក់ផ្ទះថ្មី និងសន្ទស្សន៍ថ្លៃប្រាក់ឈ្នួលនៅប្រទេសអូស្ត្រាលី ហិរញ្ញប្បទានសង្គមសរុបនៅប្រទេសចិន សន្ទស្សន៍សេដ្ឋកិច្ចឈានមុខគេ និងការវិនិយោគមូលបត្របំណុលបរទេសរបស់ប្រទេសជប៉ុន អត្រាគ្មានការងារធ្វើនៅប្រទេសបារាំង និងទុនបម្រុងអន្តរជាតិរបស់ប្រទេសឥណ្ឌា៕

ខាងក្រោម គឺជាប្រតិទិនដែលនាយកដ្ឋានស្រាវជ្រាវថវិកានឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃចន្ទ ទី១០ ខែឧសភា ឆ្នាំ២០២១</u>

- អត្រាគ្មានការងារធ្វើនៅប្រទេសទួរគី សម្រាប់ខែមីនា
- ការរំពឹងទុកអតិផរណាទំនិញប្រើប្រាស់របស់សហរដ្ឋអាមេរិក សម្រាប់ខែមេសា

<u>ថ្ងៃអង្គារ ទី១១ ខែឧសភា ឆ្នាំ២០២១</u>

- ការលក់ផ្ទះថ្មីនៅប្រទេសអូស្ត្រាលី សម្រាប់ខែមេសា
- ហិរញ្ញប្បទានសង្គមសរុបនៅប្រទេសចិន សម្រាប់ខែមេសា

<u>ថ្ងៃពុធ ទី១២ ខែឧសភា ឆ្នាំ២០២១</u>

- ការបម្រែបម្រួលភាគហ៊ុនប្រេងឆៅ API របស់សហរដ្ឋអាមេរិក សម្រាប់ថ្ងៃទី០៧ ខែឧសភា
- សន្ទស្សន៍សេដ្ឋកិច្ចឈានមុខគេរបស់ប្រទេសជប៉ុន សម្រាប់ខែមីនា

<u>ថ្ងៃព្រហស្បតិ៍ ទី១៣ ខែឧសភា ឆ្នាំ២០២១</u>

- ការវិនិយោគមូលបត្របំណុលបរទេសរបស់ប្រទេសជប៉ុន សម្រាប់ថ្ងៃទី០៨ ខែឧសភា
- សន្ទស្សន៍ថ្លៃប្រាក់ឈ្នួលនៅប្រទេសអូស្ត្រាលី ធៀបនឹងត្រីមាសមុន សម្រាប់ត្រីមាសទី១

<u>ថ្ងៃសុក្រ ទី១៤ ខែឧសភា ឆ្នាំ២០២១</u>

- អត្រាគ្មានការងារធ្វើនៅប្រទេសបារាំង សម្រាប់ត្រីមាសទី១
- ទុនបម្រុងអន្តរជាតិរបស់ប្រទេសឥណ្ឌា សម្រាប់ថ្ងៃទី០៧ ខែឧសភា